ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ៣៨..០២..២៥..០០៥..ប្រ.ព.ស.ព័ត៌មាន

ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

kamco
KOREA ASSET MANAGEMENT CORPORATION

ថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៥

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ការចុះអនុស្សរណៈយោគយល់ស្តីពី "កិច្ចសហប្រតិបត្តិការទ្វេភាគី" រវាង ធនាគារជាតិនៃកម្ពុជា និងសាជីវកម្មគ្រប់គ្រងទ្រព្យសកម្មកូរ៉េ (KAMCO)

នៅថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ ឯកឧត្តម យឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការទ្វេភាគី" ជាមួយលោក NAM JU KWON នាយកប្រតិបត្តិសាជីវកម្មគ្រប់គ្រងទ្រព្យសកម្មកូរ៉េ (KAMCO) នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ។

តាមរយៈអនុស្សរណៈយោគយល់នេះ ភាគីទាំងពីរនឹងសម្របសម្រួលកិច្ចសហការរបស់ខ្លួនតាមរយៈ៖ ១/- ការផ្តល់ព័ត៌មានផ្នែកសេដ្ឋកិច្ច និងក្របខ័ណ្ឌច្បាប់ ដើម្បីស្វែងយល់ពីបរិយាកាសផ្នែកសេដ្ឋកិច្ច និងគោលនយោបាយ ២/- ការផ្លាស់ប្តូរឯកសារស្រាវជ្រាវ និងព័ត៌មានផ្សេងៗ ៣/- ការរៀបចំវគ្គបណ្តុះបណ្តាលនិងគម្រោងស្រាវជ្រាវរួមគ្នា ៤/- ការផ្លាស់ប្តូរបទពិសោធន៍ និង ៥/- ការសម្របសម្រួលកិច្ចពិគ្រោះយោបល់ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ និងកសាងសមត្ថភាពមន្ត្រី-បុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា លើការគ្រប់គ្រងឥណទានមិនដំណើរការ។

នាថ្ងៃដដែលនេះ ឯកឧត្តម យឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា ក៏បានទទួលជួបពិភាក្សាការងារជាមួយ លោក SO YOUNG KIM អគ្គនាយករង គណៈកម្មការសេវាហិរញ្ញវត្ថុកូរ៉េ (Financial Service Commission) និង លោក SIM SEONG WOOK តំណាងសាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើកូរ៉េ (Korea Deposit Insurance Corporation)ផងដែរ។ កិច្ចពិភាក្សានេះផ្តោតលើការបន្ត

ពង្រឹងកិច្ចសហប្រតិបត្តិការ ជាពិសេសការចែករំលែកបទពិសោធន៍ការងារទាក់ទងនឹងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ការពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ ការរៀបចំយន្តការកិច្ចការពារប្រាក់បញ្ញើ និងជាពិសេសការកសាងសមត្ថភាពរបស់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា។


**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh


**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA